# ការបង្កើតកន្លែងអភិរក្សត្រី កន្លែងនេសាទសហគមន៍


**កែសម្រួលដោយៈ**

លោក **អេង ជាសាន** អនុប្រធានរដ្ឋបាលជលផល និងជាប្រធានការិយាល័យអនុវត្តគម្រោង

លោក **លី វុឌ្ឍី** ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងជាជំនួយការនៃការិយាល័យអនុវត្តគម្រោង

លោក **ពេជ ប៊ុនណា** អនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងជាមន្ត្រីត្រួតពិនិត្យតាមខេត្តនៃការិយាល័យអនុវត្តគម្រោងសម្រាប់ខេត្តកំពង់ធំ-សៀមរាប

លោក **ឈួន គីមឈា** អនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងជាមន្ត្រីត្រួតពិនិត្យតាមខេត្តនៃការិយាល័យអនុវត្តគម្រោងសម្រាប់ខេត្តកំពង់ឆ្នាំង-ពោធិ៍សាត់

លោក **អ៊ុយ ឌីន** មន្ត្រីត្រួតពិនិត្យតាមខេត្តនៃការិយាល័យអនុវត្តគម្រោងសម្រាប់ខេត្តបាត់ដំបង និងបន្ទាយមានជ័យ

**រចនាដោយៈ**

លោក **ជឿង ស៊ីសុវិន** អ្នកចាត់ការការិយាល័យគាំទ្រគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២

កញ្ញា **ពុធ ណារិន** ជំនួយការការិយាល័យគាំទ្រគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២



រូបថតក្របក្រៅ : *សកម្មភាពបោះស្លាកសញ្ញានៅសហគមន៍នេសាទព្រៃប្រស់ ខេត្តកំពង់ធំ*

ថតដោយ : *មន្ត្រីអនុវត្តគម្រោងខេត្តកំពង់ធំ*

**បោះពុម្ពដោយ:**

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ
គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២
ការិយាល័យគាំទ្រគម្រោង
ផ្ទះលេខ ៥ ផ្លូវ ៣៧០ សង្កាត់បឹងកេងកងទី១
ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧០២
ទូរសារលេខ: (៨៥៥) ២៣ ២១៦ ៥៤៧
អ៊ីម៉ែល: FAO-KH@fao.org

**សហការជាមួយ:**

រដ្ឋបាលជលផល
គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២
ការិយាល័យអនុវត្តគម្រោង
អាគារលេខ ១៨៦, មហាវិថីព្រះនរោត្តម,
ប្រអប់សំបុត្រ ៥៨២, រាជធានីភ្នំពេញ, កម្ពុជា
ទូរស័ព្ទ/ទូរសារលេខ: (៨៥៥) ២១៥ ៤៧០
អ៊ីម៉ែល: cfdd@yahoo.com

សេចក្ដីពិពណ៌នា ចំណងជើងអត្ថបទ ឬព័ត៌មានក្នុងអត្ថបទបោះពុម្ពផ្សាយនេះ មិនមែនជាទស្សនៈរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ឬក៏ជាទស្សនៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ីឡើយ ទាក់ទិននឹងច្បាប់ ឬស្ថានភាពអភិវឌ្ឍន៍របស់ប្រទេសណាមួយលើ ទឹកដី ទីក្រុង ឬតំបន់ ឬអំពីសិទ្ធិអំណាច ឬមួយទាក់ទិនទៅនឹងការកំណត់ព្រំដែន ។ ទស្សនៈយោបល់ដែលបានបង្ហាញនៅក្នុងអត្ថបទបោះពុម្ពផ្សាយនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះ ។

# សេចក្តីថ្លែងអំណរគុណ

ឯកសារជំនួយស្មារតីស្តីពី " **ការបង្កើតកន្លែងអភិរក្សក្នុងកន្លែងនេសាទសហគមន៍** " នេះត្រូវបានរៀបចំចងក្រងឡើងដោយការិយាល័យគាំទ្រគម្រោង នៃគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២ ដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់នៃអនុក្រឹត្យស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ ក្នុងការផ្តល់ជាបច្ចេកទេស និងបទពិសោធន៍ដល់អ្នកសម្របសម្រួលសហគមន៍នេសាទ ក៏ដូចជាគណៈកម្មការសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីជួយសហគមន៍នេសាទ ក្នុងការរៀបចំកន្លែងអភិរក្សរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។

ក្រុមការងារនៃការិយាល័យគាំទ្រគម្រោង សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់រដ្ឋបាលជលផល ជាពិសេសឯកឧត្តម **ណៅ ធួក** ប្រធានរដ្ឋបាលជលផល ដែលបានគាំទ្រ និងជួយសម្របសម្រួល និងធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ឥណទានសម្បទាន [ADB Loan No.1939-CAM (SF)] និងថវិកាបដិភាគរាជរដ្ឋាភិបាលកម្ពុជាសម្រាប់អនុវត្តគម្រោង ដោយមានការគាំទ្របច្ចេកទេសដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ។

ក្រុមការងារនៃការិយាល័យគាំទ្រគម្រោង សូមថ្លែងអំណរគុណដ៏ពន្លឹកដល់លោក **អេង ជាសាន** អនុប្រធានរដ្ឋបាលជលផល និងប្រធានការិយាល័យអនុវត្តគម្រោង និងលោក **លី វុទ្ធី** ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងជំនួយការ និងមន្ត្រីត្រួតពិនិត្យ: លោក **ពេជ ប៊ុនណា** លោក **ឈួន គឹមឈោ** និងលោក **អ៊ុយ ជឹង** ដែលបានជួយកែសម្រួលឱ្យឯកសារជំនួយស្មារតីនេះកាន់តែ មានភាពសុក្រឹត្យ និងសមស្របទៅនឹង ស្ថានភាពបច្ចុប្បន្ន និងសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រដល់មន្ត្រីសមភាគីគម្រោង ជំនាញរៀបចំសហគមន៍ និងជំនាញសហគមន៍នេសាទ នៅតាមបណ្តាខេត្តទាំង៥: ខេត្តបាត់ដំបង លោក **ឆន សុខា** និង លោក **ហេង ពិសិដ្ឋ** ខេត្តពោធិសាត់ លោក **ផា ស្រួយ** និង លោក **រស់ គន្ធី** ខេត្តកំពង់ឆ្នាំង លោក **ហ៊ត ស៊ីថា** និងលោក **ប៊ុន វ៉ាស៊ី** ខេត្តកំពង់ធំ លោក **តាន់ មូលី** និងលោក **ឡេង សំអាត** ខេត្តសៀមរាប លោក **ចាន់ តុង** និងកញ្ញា **កែវ សុវត្ថិភាព** ដែលបានចំណាយពេលវេលា និងកម្លាំងកាយចិត្តជួយផ្តល់អនុសាសន៍ ពិនិត្យផ្ទៀងផ្ទាត់ និងកែលំអឯកសារជំនួយស្មារតីនេះ ឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើង ។

ជាមួយគ្នានេះដែរ ក្រុមការងារនៃការិយាល័យគាំទ្រគម្រោង សូមថ្លែងអំណរគុណដល់មន្ត្រីអនុវត្តគម្រោងទាំងអស់ ដែលបានផ្តល់នូវមតិយោបល់លើឯកសារនេះ និងសូមថ្លែងអំណរគុណដោយឡែកដល់លោក **ភីតជ័រ ស៊ីស** ដែលបានជួយកែសម្រួល និងផ្តល់ជាអនុសាសន៍ក្នុងឯកសារនេះផងដែរ ។

ទោះជាយ៉ាងណាក៏ដោយ ក្រុមការងារនៃការិយាល័យគាំទ្រគម្រោងនៃគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២ សង្ឃឹមទុកជាមុន និងទទួលយកជានិច្ចរាល់មតិយោបល់កែលំអក្នុងន័យស្ថាបនាដល់យើងខ្ញុំ ។

# មាតិកាអត្ថបទ


១. សេចក្តីផ្តើម.......................................................................................................១

២. គោលបំណង........................................................................................................២

៣. និយមន័យ.........................................................................................................២

៤. ផលប្រយោជន៏នៃការបង្កើតកន្លែងអភិរក្សសហគមន៍នេសាទ.....................................................២

៥. វិធីសាស្ត្ររៀបចំកន្លែងអភិរក្សសហគមន៍នេសាទ...................................................................៣

**ជំហានទី ១ ៖ ការស្វែងយល់អំពីស្ថានភាព និងជម្រើសផ្សេងៗ**.............................................៣

**ជំហានទី ២ ៖ ការពិនិត្យកំណត់ទីតាំងនៃកន្លែងអភិរក្សសហគមន៍នេសាទ**.................................៥

**ជំហានទី ៣ ៖ ការទទួលស្គាល់ជាផ្លូវការកន្លែងអភិរក្សសហគមន៍នេសាទ**.................................៦

**ជំហានទី ៤ ៖ ការគ្រប់គ្រង ការពារ និងអភិវឌ្ឍន៍កន្លែងអភិរក្សសហគមន៍នេសាទ**......................៦

៦. បទពិសោធន៍ និងអនុសាសន៍...........................................................................................៨

៧. សន្ទានុក្រម...........................................................................................................១០

៨. ឯកសារពិគ្រោះ......................................................................................................១២

៩. ឧបសម្ព័ន្ធ.............................................................................................................១៣





*ស្លាកសញ្ញាកន្លែងអភិរក្សសហគមន៍នេសាទតាង៉ែន នៅខេត្តសៀមរាប*

## ១. សេចក្ដីផ្ដើមៈ

នៅក្នុងដំណើរកំណែទម្រង់វិស័យជលផល រាជរដ្ឋាភិបាលសម្រេចលប់ និងកាត់បន្ថយនាទីឡូត៍នេសាទប្រមាណ ៥៦ ភាគរយសម្រាប់ទុកជូនប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ដោយបង្កើតនូវសហគមន៍នេសាទដើម្បីចូលរួមចំណែកការពារ និងអភិរក្សធនធានធម្មជាតិជាពិសេសធនធានជលផល តាមរយៈអនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ។

សហគមន៍នេសាទនីមួយៗរមែងជួបប្រទះនូវបញ្ហាជាច្រើន ក្នុងការគ្រប់គ្រងធនធានជលផល នៅក្នុងកន្លែងនេសាទរបស់ខ្លួន ហើយចាំបាច់ត្រូវស្វែងរកមធ្យោបាយផ្សេងៗដើម្បីគ្រប់គ្រងឱ្យមានប្រសិទ្ធភាព។ ក្នុងនោះមានដូចជា ÷ សកម្មភាពល្បាត ការអប់រំផ្សព្វផ្សាយ ការកំណត់ឧបករណ៍ប្រើប្រាស់ ការបង្កើនជីវភាពរបស់ប្រជាពលរដ្ឋ ក្នុងសហគមន៍ និងការបង្កើតកន្លែងអភិរក្ស ដែលជាមធ្យោបាយមួយដ៏សំខាន់ ហើយមានការគាំទ្រដោយអនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ ដូចមានចែងក្នុង ***ជំពូកទី ៣ មាត្រា ១០ កថាខណ្ឌទី៣*** សហគមន៍នេសាទមានតួនាទី និងភារៈកិច្ច " *ចូលរួមបង្កើត**កន្លែងអភិរក្ស**ក្នុងកន្លែងនេសាទសហគមន៍ ថែរក្សា ការពារ និងដាំដុះព្រៃលិចទឹក និងព្រៃកោងកាង ស្ដារព្រែក បឹងដែលរីងរាក់ ដើម្បីកែលំអប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានជលផលឡើងវិញ* "។

ការបង្កើតកន្លែងអភិរក្សអាចមានផលប្រយោជន៍ ដល់ការការពារជីវចម្រុះ និងប្រភេទមច្ឆជាតិដែលរងការគំរាមកំហែង ឬជិតផុតពូជ ម្យ៉ាងវិញទៀតអាចការពារត្រីមេពូជ និងធ្វើឱ្យត្រីព្រមទាំងវារីសត្វ-រុក្ខជាតិផ្សេងៗឱ្យមានភាពសម្បូរឡើងវិញ ដើម្បីជាផលប្រយោជន៍ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

កន្លែងអភិរក្សរបស់សហគមន៍នេសាទ ជាប្រភេទមួយក្នុងចំណោមតំបន់/កន្លែងការពារ និងអភិរក្សជាច្រើនបែបដូចខាងក្រោម :

- តំបន់រ៉ាមសារ (Ramsar site)
- តំបន់ដីសើម (Wetland)
- កេរ្តិ៍ដំណែល ស្ទឹង-ទន្លេ (Heritage Rivers)
- ឧទ្យានជាតិ (National Park)
- តំបន់ការពារសមុទ្រ (Marine Protected Area)
- តំបន់បតិកភណ្ឌពិភពលោក (World Heritage Site)
- តំបន់ការពារប្រភេទក្នុងស្រុក (Indigenous Protected Area)
- កន្លែងអភិរក្សជលផល (Fish Sanctuary)
- កន្លែងអភិរក្សសហគមន៍នេសាទ (Community Fisheries Fish Sanctuary)

មកដល់ពេលនេះ សហគមន៍នេសាទមួយចំនួនបាននឹងកំពុងដំណើរការបង្កើតកន្លែងអភិរក្សរបស់ខ្លួនទៅតាមវិធីសាស្ត្ររៀងៗខ្លួន ដូចជាការកំណត់ទីតាំង បោះបង្គោល ដាក់ស្លាកសញ្ញា ដាក់គល់ឈើ ។ល។

ដើម្បីសម្រួលដល់ការងារនេះ ការិយាល័យគាំទ្រគម្រោងនៃគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២ បានផ្តួចផ្តើមរៀបចំសេចក្តីព្រាងឯកសារជំនួយស្មារតីនេះឡើង ដោយសង្ឃឹមថាអាចជាមូលដ្ឋានគន្លឹះ និងបទពិសោធន៍ ដែលអាចជួយដល់សហគមន៍នេសាទ ក្នុងការបង្កើតកន្លែងអភិរក្សរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងជោគជ័យ ។

## ២. គោលបំណង:

គោលបំណងនៃឯកសារជំនួយស្មារតីនេះគឺ:

- ជាជំនួយស្មារតីសម្រាប់ជាការពិចារណាក្នុងការរៀបចំជ្រើសរើសកន្លែងអភិរក្ស
- ចែករំលែកបទពិសោធន៍ និងលក្ខណៈបច្ចេកទេសដល់សហគមន៍នេសាទ ក្នុងការបង្កើតកន្លែងអភិរក្ស
- ចូលរួមថែរក្សា និងការពារធនធានធម្មជាតិ ជាពិសេសធនធានជលផលប្រកបដោយការទទួលខុសត្រូវខ្ពស់

## ៣. និយមន័យ:

" ***កន្លែងអភិរក្ស*** " ចំពោះពាក្យនេះពុំមានពន្យល់នៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទទេ ។ ដោយឡែកនៅក្នុងច្បាប់ស្តីពីជលផល ក្នុងជំពូកទី៣ អំពីដែននេសាទ និងជំពូកទី ៥ អំពីការការពារ និងអភិរក្សជលផល មានពាក្យស្រដៀងគ្នាគឺ " ***កន្លែងអភិរក្សជលផល*** " ដែលបានពន្យល់ក្នុងឧបសម្ព័ន្ធមានន័យថា " *សំដៅដល់ចំណាត់ថ្នាក់ នៃដែននេសាទទឹកសាប ឬសមុទ្រ ហើយត្រូវបានកំណត់ភូមិសាស្ត្រ ជាក់លាក់សម្រាប់វារីសត្វ ឬរុក្ខជាតិជ្រកពួន ពងកូន រីកធំធាត់ ឬរីកលូតលាស់។ កន្លែងអភិរក្សជលផលជាថ្នាលពូជ និងជាតំបន់ការពារធនធានជលផលដែលពុំអាចអនុញ្ញាតឱ្យប្រព្រឹត្តសកម្មភាព ដែលនាំឱ្យមានផលប៉ះពាល់ដល់ធនធានជលផលបានឡើយ ក្រៅពីការស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រ ជលផលស្របតាមគោលការណ៍ដ៏ត្រឹមត្រូវ* " ។

យើងឱ្យនិយមន័យ " ***កន្លែងអភិរក្ស*** " របស់សហគមន៍នេសាទគឺជា " *កន្លែងនេសាទមួយក្នុងសហគមន៍នេសាទ ដែលត្រូវកំណត់សម្រាប់អភិរក្ស ជាជម្រកឱ្យវារីសត្វ ឬរុក្ខជាតិ គ្រប់ប្រភេទ រស់នៅ ពងកូន និងធំធាត់ ជាពិសេសសម្រាប់រក្សាទុក ពូជមច្ឆជាតិ ដែលពុំអាចអនុញ្ញាតឱ្យប្រព្រឹត្តសកម្មភាព នាំឱ្យមានផលប៉ះពាល់ដល់ធនធានជលផលបានឡើយ* " ។

## ៤. ផលប្រយោជន៍នៃការបង្កើតកន្លែងអភិរក្សសហគមន៍នេសាទ:

ការបង្កើតកន្លែងអភិរក្ស និងការពារបានល្អអាចមានផលប្រយោជន៍ផ្សេងៗដល់សហគមន៍ដូចជា :

- សម្បូរត្រី សម្រាប់ពូជធារនៅឆ្នាំបន្ទាប់
- ប្រភេទត្រីកម្រ និង ជិតផុតពូជអាចមានកន្លែងរស់នៅ
- ធ្វើឱ្យមច្ឆជាតិ វារីរុក្ខជាតិ និងសត្វគ្រប់ប្រភេទសម្បូរឡើងវិញ

- ថែរក្សា និងបង្កើនបានផលស្តុកសម្រាប់ការប្រើប្រាស់យូរអង្វែង
- លើកកំពស់ក៏រិតជីវភាពរស់នៅដល់ប្រជានេសាទ
- ធានាប្រភពប្រូតេអ៊ីន និងជីវជាតិដល់ប្រជាជនពលរដ្ឋ
- ផ្តល់ផលប្រយោជន៏ផ្សេងៗទៀត ។

## ៥. វិធីសាស្ត្ររៀបចំកន្លែងអភិរក្សសហគមន៍នេសាទ

សហគមន៏នេសាទនីមួយៗអាចរៀបចំកន្លែងអភិរក្សតាមវិធីសាស្ត្រផ្សេងៗគ្នា ប៉ុន្តែឯកសារជំនួយស្មារតីនេះនឹងបង្ហាញពីដំណើរការមួយដែលធ្លាប់ប្រើប្រាស់មានប្រសិទ្ធភាពដោយចែកចេញជា ៤ ជំហាន ។ ជំហាននីមួយៗនឹងត្រូវបានលើកឡើងម្តងមួយៗ មកធ្វើការពន្យល់លំអិតអំពីអ្វីដែលគួរធ្វើក្នុងជំហាននោះ។ ជំហានទាំងនោះរួមមាន:

ជំហានទី ១ : ការស្វែងយល់អំពីស្ថានភាព និងជម្រើសផ្សេងៗ

- ការប្រជុំពិភាក្សាផ្ទៃក្នុងសហគមន៍នេសាទ
- ការស្នើសុំជំនួយបច្ចេកទេស
- ការចុះពិនិត្យដោយមន្ត្រីជំនាញ

ជំហានទី ២ : ការពិនិត្យ និងកំណត់ទីតាំងនៃកន្លែងអភិរក្សសហគមន៍នេសាទ

ជំហានទី ៣ : ការទទួលស្គាល់ជាផ្លូវការកន្លែងអភិរក្សសហគមន៍នេសាទ

ជំហានទី ៤ : ការគ្រប់គ្រងកន្លែងអភិរក្សសហគមន៍នេសាទ

- ការរៀបចំបទបញ្ញាផ្ទៃក្នុង ឬបម្រាម និងស្លាកសញ្ញា
- ការផ្សព្វផ្សាយ
- ការរៀបចំក្រុមល្បាត និងរោងយាមល្បាត
- ការរៀបចំជម្រកសិប្បនិម្មិត និងស្តារឱ្យជ្រៅឡើងវិញ

### ជំហានទី ១ : ការស្វែងយល់អំពីស្ថានភាព និងជម្រើសផ្សេងៗ

សហគមន៏នេសាទមានជម្រើសជាច្រើន ក្នុងការគ្រប់គ្រងកន្លែងនេសាទសហគមន៏ ហើយសមាជិកសហគមន៏ទាំងអស់គួរតែចូលរួមវិភាគបញ្ហា និងឱកាសដែលសហគមន៏កំពុងតែជួបប្រទះ និងវិភាគជម្រើសផ្សេងៗ ។ ប្រសិនសមាជិកទាំងអស់ចូលរួមក្នុងការវិភាគ និងផ្តល់មតិយោបល់ នោះគាត់នឹងមានភាពជាម្ចាស់ការលើការគ្រប់គ្រង និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព ។

គណៈកម្មការសហគមន៏នេសាទអាចដឹកនាំសមាជិកស្វែងយល់ពី :

- តើត្រីធ្វើចរាចរក្នុងតំបន់នោះយ៉ាងដូចម្តេច ? ប្រភេទត្រីផ្សេងៗពងកូននៅឯណា? រកចំណីនៅឯណា ?

ជាពិសេសគិតអំពីទំនាក់ទំនងរវាងតំបន់ព្រៃលិចទឹក អន្លង់ លំហបឹង ។ល។ (អាចប្រើវិធីសាស្ត្រ PRA)

- តើកន្លែងណាដែលមានសារៈសំខាន់ច្រើនជាងគេ សម្រាប់ការអភិរក្សជីវចម្រុះ? ដូចជាៈ ត្រី ព្រៃលិចទឹក សត្វស្លាប និងសត្វប្រភេទផ្សេងៗទៀត?
- តើមានជម្រើសអ្វីខ្លះក្នុងការគ្រប់គ្រងកន្លែងនេសាទសហគមន៍? តើការបង្កើតកន្លែងអភិរក្សមានផលប្រយោជន៍អ្វី បើប្រៀបធៀបនឹងជម្រើសផ្សេងៗទៀត?
- តើកន្លែងណាខ្លះ ដែលកន្លងមកប្រជាពលរដ្ឋបានគ្រប់គ្រងតាមលក្ខណៈប្រពៃណី ដោយមានជំនឿ ឬជាតំបន់អភិរក្ស ?
- ក្នុងកន្លែងនេសាទសហគមន៍ តើមានកន្លែងណាខ្លះដែលអាចរៀបចំជាកន្លែងអភិរក្ស? តើការរៀបចំកន្លែងអភិរក្សមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះដល់ប្រជាពលរដ្ឋ?
- តើមានអ្នកពាក់ព័ន្ធណាខ្លះ ដែលប្រើប្រាស់កន្លែងនេសាទទាំងនោះ?
- បើសិនបង្កើតកន្លែងអភិរក្ស តើគួរហាមឃាត់ ឬ អនុញ្ញាតិឱ្យមានសកម្មភាពអ្វីខ្លះនៅទីនោះ ?

សមាជិកសហគមន៍នេសាទគួរតែគិតខ្លួនឯងអំពីលក្ខណៈវិនិច្ឆ័យសម្រាប់បង្កើតកន្លែងអភិរក្ស។ ខាងក្រោមនេះគឺ ជាលក្ខណៈវិនិច្ឆ័យមួយចំនួនដែលជាបទពិសោធន៍ធ្លាប់អនុវត្តកន្លងមក ដើម្បីជាជំនួយស្មារតីសម្រាប់អ្នកសម្របសម្រួល :

- ជាបឹងបួរ ត្រពាំង ស្រះ ព្រែក ស្ទឹង ឬទន្លេ...ដែលមានទឹកទាំងរដូវប្រាំង និងរដូវវស្សា (ពី៥-១០ ឆ្នាំ)
- កន្លែងដែលមានជម្រៅទឹកជ្រៅជាងគេបំផុតនៅរដូវប្រាំង (យ៉ាងហោចក៏ 0,៨ ទៅ ១,២ម៉ែត្រ)
- មានប្រព័ន្ធផ្លូវទឹកអាចបង្កលក្ខណៈល្អប្រសើរដល់ការធ្វើចរាចរចេញ-ចូលរបស់ត្រី
- ជាទីជម្រកដ៏ប្រសើរដល់ជីវសាស្ត្រចម្រុះ ដូចជាៈ វារីសត្វ (មានប្រភេទត្រី សត្វ បក្សីកម្ររស់នៅ) និង វារីរុក្ខជាតិ (ព្រៃលិចទឹក...)
- មានប្រវត្តិយូរលង់ និងមានប្រពៃណី ឬ ជំនឿផ្សេងៗ (ស្រះក្នុងវត្ត កន្លែងអារក្ស-អ្នកតា ត្រីបារមី...)
- មានការគាំទ្រពីអ្នកពាក់ព័ន្ធទាំងអស់ (អ្នកភូមិ ឬសហគមន៍នេសាទក្បែរខាង...)
- មានការស្នើសុំ និងពេញចិត្តដោយសហគមន៍នេសាទផ្ទាល់ មិនមែនដោយប្រយោល ឬបញ្ជាពីអ្នកខាងក្រៅ
- មានទីតាំងភូមិសាស្ត្រនៅក្បែរភូមិ (សហគមន៍នេសាទ )
- មានទីតាំងភូមិសាស្ត្រមិនមែនជាប្រភពទឹកស្រោចស្រពកសិកម្មនៅរដូវប្រាំង
- មានលក្ខណៈងាយស្រួលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រង ។

## ជំហានទី ២ : ការពិនិត្យ និងកំណត់ទីតាំងនៃកន្លែងអភិរក្សសហគមន៍នេសាទ

នៅពេលដែលសមាជិកសហគមន៍នេសាទឯកភាពគ្នាថា ចង់បង្កើតកន្លែងអភិរក្សនៅកន្លែងណាមួយ គួរតែរៀបចំសំណើសុំជំនួយបច្ចេកទេសពីស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះទៅពិនិត្យកន្លែងនោះជាក់ស្តែង ស្វែងយល់ពីសក្តានុពលនៃការរៀបចំកន្លែងអភិរក្សនៅទីនោះ ជាពិសេសថាតើអាចនាំមកនូវទំនាស់អ្វីខ្លះ ឬផលប៉ះពាល់អ្វីខ្លះ? រួចហើយផ្តល់មតិយោបល់ដល់សហគមន៍ និងធ្វើការគាំទ្រដល់សហគមន៍ក្នុងការរៀបចំកន្លែងអភិរក្ស ។

ក្រុមការងារនោះគួរចុះពិនិត្យដល់ទីកន្លែងជាក់ស្តែង ជាពិសេសនៅវដ្ដូវប្រាំង ដើម្បីពិនិត្យលើ :

- ជម្រៅទឹកនៅកណ្តាលរដូវប្រាំង (ធ្វើការវាស់ជាក់ស្តែង)
- ទំហំផ្ទៃទឹកនៅរដូវប្រាំង ថាតើមានទំហំសមស្របឬទេ?
- គុណភាពទឹក តើអាចធានាបានដល់ការរស់នៅរបស់វារីសត្វ-រុក្ខជាតិនៅរដូវប្រាំងឬទេ?
- តើមានប្រភេទត្រី និងវារីសត្វ-រុក្ខជាតិនានា អ្វីខ្លះដែលធ្លាប់នេសាទ ឬប្រមូលបាន ឬរស់នៅទីនោះ?
- តើព្រៃលិចទឹកមានចំនួនប៉ុន្មានភាគរយ នៅជុំវិញទីកន្លែងនោះ?
- តើមានការរុករាន ទន្ទ្រាន កាន់កាប់ កន្លែងនោះ ដោយធ្វើសកម្មភាពផ្សេងៗ ដូចជាការធ្វើកសិកម្មឬទេ?
- តើនៅជិត ឬឆ្ងាយដែលអាចប៉ះពាល់ដល់កន្លែងអភិរក្សជលផលដែរឬទេ?
- តើអ្នកណាខ្លះធ្លាប់ប្រកបមុខរបរនេសាទនៅទីនោះ?
- តើមានភាពងាយស្រួល ឬពិបាកក្នុងការយាមល្បាត?

ក្រោយពីការសម្រេចចិត្តជ្រើសរើសយកកន្លែងនេសាទណាមួយ ដើម្បីរៀបចំកន្លែងអភិរក្ស និងបានកំណត់បទប្បញ្ញត្តិរួចហើយ គណៈកម្មការសហគមន៍នេសាទ មន្ត្រីជំនាញជលផល អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធអាចចុះទៅកំណត់ទីតាំង ជាកន្លែងអភិរក្ស ដោយអនុវត្តវិធីសាស្ត្រដូចខាងក្រោម:

### ១. ការចុះកំណត់និយាមកា និងការគូសព្រាងផែនទី

ជំនាញជលផលមានភារៈកិច្ចជួយដល់សហគមន៍នេសាទ ក្នុងការកំណត់និយាមកាតាមព្រំប្រទល់របស់កន្លែងអភិរក្សហើយអាចជួយណែនាំថា តើត្រូវកំណត់ចំណុចប៉ុន្មាន ទើបអាចគូសចេញជាផែនទីបាន? ពេលចុះកំណត់ចំណុចនិយាមកាគួរតែមានការចូលរួមពីគណៈកម្មការសហគមន៍នេសាទ សមាជិកសហគមន៍នេសាទ ចាស់ទុំ ព្រឹទ្ធាចារ្យ ជំនាញជលផល និងអាជ្ញាធរមូលដ្ឋាន ។

ពេលដែលកំណត់ចំណុចរួច ជំនាញជលផលអាចជួយរៀបចំផែនទី ហើយគួរតែផ្សព្វផ្សាយផែនទីនោះ ព្រមទាំង បទបញ្ញាតិជាសាធារណៈរយៈពេលមួយកំណត់(១៥ថ្ងៃ ឬ១ខែ) ដើម្បីទទួលបានការគាំទ្រទាំងស្រុង ឬមានមតិយោបល់លើទីតាំងកន្លែងនេសាទ ឬយ៉ាងណា?

### ២. ការបោះបង្គោលព្រំប្រទល់ និងដាក់ស្លាកសញ្ញា

ក្រោយពីមានផែនទី និងឯកភាពចំណុចនិយាមកាហើយ ក្រុមការងារត្រូវចុះបោះបង្គោលកំណត់ព្រំប្រទល់កន្លែងអភិរក្ស នូវព្រំទាំងនោះដោយបង្គោលឈើ ឬស៊ីម៉ង់ ។ ជ្រើសរើសទីកន្លែងសមស្រប១ ឬ ២កន្លែងដើម្បីលើកស្លាកសញ្ញា ដែលមានអត្ថន័យថា: " ***កន្លែងអភិរក្សសហគមន៍នេសាទ....*** " ដូចមានក្នុងគំរូនៃឧបសម្ព័ន្ធ។

ស្លាកសញ្ញានេះអាចសរសេរបទប្បញ្ញត្តិ ឬ បម្រាមទាំងឡាយ ដែលពាក់ព័ន្ធនឹងកន្លែងអភិរក្សផងដែរ ។ បើសិនសហគមន៍គ្មានការឧបត្ថម្ភពីប្រភពណាទេ ក៏អាចធ្វើបង្គោល និងស្លាកសញ្ញាជាលក្ខណៈសាមញ្ញដោយប្រើធនធានដែលមានក្នុងសហគមន៍របស់ខ្លួន ។

***<u>សំគាល់:</u>*** ស្លាកសញ្ញាភាគច្រើនកន្លងមកមានចំណងជើងផ្សេងគ្នា១ ច្រើនប្រើពាក្យ " ***តំបន់...*** " ដែលមិនសមស្របនឹងអនុក្រឹត្យស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ ដែលមានពាក្យថា " ***កន្លែងអភិរក្ស*** " ដូច្នេះត្រូវពិនិត្យ និងពិចារណាពេលធ្វើស្លាកសញ្ញាទាំងនេះ។

### ជំហានទី ៣: ការទទួលស្គាល់ជាផ្លូវការកន្លែងអភិរក្សសហគមន៍នេសាទ

ក្រោយពីកំណត់បានកន្លែងអភិរក្សសហគមន៍នេសាទសមស្របទៅនឹងផែនការគ្រប់គ្រង សហគមន៍នេសាទគួរធ្វើការស្នើសុំមកការិយាល័យជំនាញ ឬអាជ្ញាធរដែនដីដើម្បីទទួលស្គាល់ជាផ្លូវការ និងចូលរួមជួយគាំទ្រក្នុងការគ្រប់គ្រង និងអភិរក្សកន្លែងអភិរក្សនេះ ។ សហគមន៍នេសាទត្រូវត្រៀមឯកសារមួយចំនួន ដើម្បីទទួលបានការគាំទ្រជាផ្លូវការ ឯកសារទាំងនោះរួមមាន:

- បង្ហាញពីគោលបំណង ក្នុងការអភិរក្សកន្លែងនេសាទ
- កំណត់ហេតុរបស់ក្រុមការងារ ក្រោយពេលចុះកំណត់ជាក់ស្តែង
- ផែនទី គំនូសតាងទីតាំងកន្លែងអភិរក្ស
- លិខិតស្នើសុំបង្កើតកន្លែងអភិរក្ស (ឈ្មោះ ទំហំ បណ្តោយ ទទឹង...)
- ឯកសារគាំទ្រ និងជំនួយផ្សេង១ ដែលចាំបាច់ ។

### ជំហានទី ៤: ការគ្រប់គ្រង ការពារ និងអភិវឌ្ឍន៍កន្លែងអភិរក្សសហគមន៍នេសាទ

បទពិសោធន៏កន្លងមក កន្លែងអភិរក្សសហគមន៍នេសាទមួយចំនួនគ្រប់គ្រង ការពារ និងអភិវឌ្ឍន៍បានល្អប្រសើរ តែមួយចំនួនតូចត្រូវទទួលបរាជ័យ ក្រោយពីបង្កើតរួច ដូច្នេះដើម្បីជៀសវាងការបរាជ័យ យើងគួរអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម:

## ១. ការរៀបចំបទបញ្ជាផ្ទៃក្នុង ឬបម្រាម និងស្លាកសញ្ញា

ក្រោយពីពិនិត្យជាក់ស្តែងឃើញថា កន្លែងដែលសហគមន៍នេសាទចង់បង្កើតជាកន្លែងអភិរក្សនោះ មិនបង្កឱ្យមានផលប៉ះពាល់ខ្លាំងលើក្រុមណាមួយ ឬបង្កជាទំនាស់ខ្លាំងក្លាពេកទេ នោះអាចកំណត់ជាបទប្បញ្ញត្តិ ឬបម្រាមជាលក្ខណៈផ្លូវការ សម្រាប់ការប្រើប្រាស់ធនធាននៅកន្លែងអភិរក្សនោះ ។

គណៈកម្មការសហគមន៍នេសាទ គួរតែធ្វើការពិគ្រោះយោបល់ ជាមួយសមាជិកសហគមន៍ក្នុងការកំណត់បទប្បញ្ញត្តិ ឬបម្រាម ដោយសួរជាសំណួរ ថាតើប្រជាពលរដ្ឋអាចចេញចូលកន្លែងអភិរក្សបានទេ? តើអាចប្រើប្រាស់ធនធានអ្វីខ្លះនៅក្នុងកន្លែងនោះ? បើសិនប្រព្រឹត្តិផ្ទុយពីបទបញ្ញាតិ ត្រូវមានវិន័យយ៉ាងដូចម្តេច? ហើយគួរតែឱ្យអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធទទួលស្គាល់បទប្បញ្ញត្តិ ឬបម្រាមនោះ។

កន្លែងអភិរក្សខ្លះ សហគមន៍ហាមមិនឱ្យប្រជាពលរដ្ឋចេញចូលឡើយ កន្លែងខ្លះហាមប្រើប្រាស់ឧបករណ៍នេសាទខុសពីមង ឬសន្ទូច ឬអាចមានការកំណត់ការប្រើប្រាស់ផ្សេងៗទៀត ។

ចំណុចមួយចំនួនដែលត្រូវពិចារណា :

- បទបញ្ជាផ្ទៃក្នុង ឬបម្រាមត្រូវមានលក្ខណៈច្បាស់លាស់ និងអាចទទួលយកបាន( មើលគំរូក្នុងឧបសម្ព័ន្ធ)
- ត្រូវពិនិត្យពីសិទ្ធិរបស់សហគមន៍នេសាទ ជៀសវាងបទបញ្ជាផ្ទៃក្នុង ឬបម្រាមនេះប្រឆាំងនឹងច្បាប់
- ស្លាកសញ្ញាត្រូវមានអត្ថន័យស្របទៅនឹងអនុក្រឹត្យ " ***កន្លែងអភិរក្ស*** "
- ត្រូវរើសទីតាំងដាក់ស្លាកសញ្ញាឱ្យបានសមស្រប នៅតាមច្រកចេញចូល ដែលងាយមើលឃើញ
- គួរមានរូបភាពមួយចំនួនដើម្បីទាក់ទាញអ្នកដែលចូលក្នុងកន្លែងនោះ
- ស្លាកសញ្ញាគួរភ្ជាប់ជាមួយបទបញ្ជាផ្ទៃក្នុង ឬបម្រាម ឬធ្វើដោយឡែក
- ផាកពិន័យដល់ជនល្មើសឱ្យបានម៉ឺងម៉ាត់ ដើម្បីជាការព្រមានដល់អ្នកល្មើសផ្សេងទៀត។

## ២. ការផ្សព្វផ្សាយ

- ពង្រីកការងារផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាពិសេសដល់អ្នកមកពីក្រៅ/ឆ្ងាយ តាមរយៈការពន្យល់ផ្ទាល់ ខិតបណ្ណ ផ្ទាំងរូបភាព ការប្រជុំតាមក្រុមតូចៗ ក្នុងកម្មវិធីបុណ្យទាន ។ល។
- បំផុស និងទាក់ទាញឱ្យប្រជារាស្ត្រចូលរួមជួយថែរក្សា និងការពារកន្លែងអភិរក្ស
- ពន្យល់ពីសារៈសំខាន់នៃកន្លែងអភិរក្ស លើកឧទាហរណ៍ជាក់ស្តែង ( បើអភិរក្សបានត្រីសម្បូរមែន)
- រៀបចំកន្លែងអភិរក្សឱ្យក្លាយជាកន្លែងទេសចរណ៍
- ស្វែងរកជំនួយឧបត្ថម្ភគាំទ្រទាំងស្មារតី និងថវិកា ពីស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីជួយក្នុងការគ្រប់គ្រងកន្លែងអភិរក្សរបស់ខ្លួនដើម្បីធានាបានចីរភាពនៃធនធានជលផល ។

### ៣. ការរៀបចំក្រុមល្បាត និងរោងយាម

- រៀបចំក្រុមល្បាតដោយឡែក ដោយមានការឧបត្ថម្ភពិសេសសម្រាប់យាមល្បាតនៅរដូវប្រាំង
- ធ្វើប៉ុស្តិ៍ ឬរោងយាម ដោយយាមល្បាតជាប្រចាំទាំងរដូវវស្សា និងរដូវប្រាំង

### ៤. ការរៀបចំជម្រកសិប្បនិម្មិត និងស្តារឱ្យជ្រៅឡើងវិញ

- ដាក់ជម្រកសិប្បនិម្មិតដើម្បីឱ្យត្រី និងវារីសត្វទាំងពួងមកជ្រកពួន និងជាឧបសគ្គដល់បទល្មើសនេសាទ ។ ជម្រកសិប្បនិម្មិតទាំងនោះគួរមានដូចជា: សម្រាស់ គល់ឈើចាស់ៗ បង្គោល ទូកចាស់ៗ លូប្រហោង...។
- លើកគម្រោងជីកស្តារកន្លែង/ផ្នែកខ្លះនៃកន្លែងអភិរក្សឱ្យកាន់តែជ្រៅដើម្បីឱ្យត្រី និងវារីសត្វនានាអាចរស់នៅបាននារដូវប្រាំង ។
- រកប្រភេទពូជត្រីដែលកំពុងរងគ្រោះថ្នាក់ និងវារីសត្វមួយចំនួនមានដូចជាៗ អណ្តើក កន្ធាយ អន្ទេងភេ...មកលែងក្នុងកន្លែងអភិរក្សដើម្បីជាពូជធារ ។
- ធ្វើការវាយតម្លៃរៀងរាល់ឆ្នាំពីសក្តានុពលភាពនៃកន្លែងអភិរក្ស តើសមស្របឬទេ? តើមានប្រភេទត្រីមករស់នៅច្រើនឬទេ ជាពិសេសនៅរដូវប្រាំង?
- ផ្តល់ចំណីបន្ថែមដល់មច្ឆា និងវារីសត្វដែលរស់នៅក្នុងកន្លែងអភិរក្សមាន បាយ កន្ទក់ស្ងោ ចំណីគ្រាប់...ជាពិសេសនៅរដូវវស្សា ។

## ៦. បទពិសោធន៍ និងអនុសាសន៍:

យើងត្រូវតែដឹងឱ្យបានច្បាស់ទៅលើបទពិសោធន៍មួយចំនួន ដែលបានអនុវត្តកន្លងមក ក្នុងការរៀបចំបង្កើតកន្លែងអភិរក្ស ដែលជួយឧបត្ថម្ភដោយគម្រោងនានា និងដោយស្ថាប័នជំនាញ ដែលកន្លែងអភិរក្សមួយចំនួនទទួលបានជោគជ័យគួរជាទីមោទនភាព និងមួយចំនួនទៀតទទួលបានបរាជ័យដែលគួរឱ្យសោកស្តាយនឹងគួរឱ្យជៀសវាង ។

កត្តាដែលបណ្តាលឱ្យទទួលបានបរាជ័យនោះ មួយចំនួនធំបណ្តាលមកពីការជ្រើសរើសទីតាំងពុំបានសមស្រប និងធ្វើឡើងដោយមិនតម្រូវទៅនឹងអ្វីដែលជាគោលបំណង ឬឆន្ទៈរបស់សហគមន៍នេសាទចង់បង្កើត ម្យ៉ាងទៀតធ្វើតាមបែបមជ្ឈការ និងដោយគ្មានការចូលរួមពីសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធ ។

ខាងក្រោមនេះជាបទពិសោធន៍ទាំងឡាយ ទាំងជោគជ័យ និងបរាជ័យ និងអនុសាសន៍មួយចំនួនដើម្បីទុកជាគន្លឹះ ក្នុងការរៀបចំ និងគ្រប់គ្រងកន្លែងអភិរក្សប្រកបដោយចីរភាពៈ

| កត្តាជោគជ័យ | កត្តាបរាជ័យ | អនុសាសន៍ |
|---|---|---|
| - ភូមិសាស្ត្រសមស្រប ងាយក្នុងការការពារ និងគ្រប់គ្រង (ជិតភូមិ) | - ទីតាំងឆ្ងាយពីភូមិ(សហគមន៍) ដែលមិនអាចការពារ និងគ្រប់គ្រងបាន | - ជ្រើសរើសទីតាំងណាដែលងាយស្រួលដល់សហគមន៍ក្នុងការគ្រប់គ្រង (ចុងភូមិ ឬចុងស្រែ...) |
| - ពុំមានពាក់ព័ន្ធនិងស្ថាប័ន/ក្រុមហ៊ុនអភិវឌ្ឍន៍នានា | - ទីតាំងមិនមែនជាបំណងរបស់សហគមន៍ចង់បាន ។ បង្កើតឡើងដោយគម្រោង ឬការិយាល័យជំនាញ | - គួរពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធពីទីតាំងដែលសហគមន៍ចង់បាន |
| - ទំហំសមស្រប (តូចខ្លឹម) | - ទំហំលោភលន់ (ធំពេក) និងហាមនេសាទទាំងស្រុង | - មិនត្រូវលោភលន់ទំហំក្នុងការកំណត់កន្លែងអភិរក្សទេ |
| - ទីតាំងមានអបិយជំនឿ (ស្រះវត្ត បឹងអារក្ស-អ្នកតា ត្រីមានបារមី...) | - ក្បែរ ឬជាប់ទីតាំងអភិវឌ្ឍន៍នានា ងាយរងនូវការទន្ទ្រាន និងបង្កទំនាស់ | - កំណត់យកតែផ្នែកចំបងដែលមានទំហំសមស្រប និងងាយក្នុងការការពារ និងអភិរក្ស (ការពារបាន ១០០ % នៅរដូវប្រាំង) |
| - ជាទីតាំងបំណងប្រាថ្នារបស់សហគមន៍ (មានឆន្ទៈ និងសន្យាការពារ) | - គ្មានព្រំប្រទល់ច្បាស់លាស់/គ្មានស្លាកសញ្ញា បទបញ្ជា/បម្រាម | - ត្រូវមានព្រំប្រទល់ច្បាស់លាស់ដោយបោះបង្គោល ឬតម្រុយ |
| - មានស្លាកសញ្ញា បទបញ្ជា/បម្រាម | - ទីតាំងដែលរាស្ត្រធ្លាប់រកនេសាទជាយូរយារមកហើយ | -ត្រូវមានស្លាកសញ្ញា បម្រាម/បទបញ្ជា ដែលមានរូបភាពផ្សព្វផ្សាយ-អប់រំភ្ជាប់ជាមួយ |
| - គណៈកម្មការសហគមន៍នេសាទមានឆន្ទៈមោះមុតក្នុងការអភិរក្ស | - គ្មានការចូលរួមការពារ និងអភិរក្សជាក់លាក់ពីសហគមន៍នេសាទ | - ត្រូវលើកទឹកចិត្តដល់ក្រុមល្បាតទាំងស្មារតី និងទាំងសម្ភារៈ |
| - មានការយាមល្បាតជាប្រចាំដោយក្រុមល្បាត | - គ្មានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន/ស្ថាប័នជំនាញ ឬអ្នកពាក់ព័ន្ធ | - គួរមានតូប/ប៉មយាម បើមានលទ្ធភាព |
| | - គ្មានក្រុមល្បាតយាមកាម និងសម្ភារៈ/មធ្យោបាយ | - ត្រូវមានជម្រកសិប្បនិម្មិត ដើម្បីជាកន្លែងជ្រកពួករបស់មច្ឆជាតិ និងជាឧបសគ្គដល់ការល្មើសនេសាទ ។ |

## ៧. សន្ទានុក្រម:

***កន្លែងនេសាទបម្រុង :*** សំដៅដល់ផ្នែកមួយនៃដែននេសាទទឹកសាបដែលមិនមែនជាឡូត៍នេសាទ កន្លែងអភិរក្សជលផល នាទីព្រៃលិចទឹក កន្លែងនេសាទគ្រួសារ ឬទំនាបលិចទឹកក្នុងរដូវដំឡើង។ កន្លែងនេសាទ បម្រុងមិនត្រូវបានធ្វើការចាត់ថ្នាក់ ជាតំបន់គ្រប់គ្រងជលផលជាក់លាក់ឡើយ ហើយត្រូវបានអនុញ្ញាតឱ្យធ្វើនេសាទបានតែការនេសាទ ២ប្រភេទ គឺការនេសាទជាលក្ខណៈគ្រួសារ និងការនេសាទជាលក្ខណៈសិប្បកម្ម។ កន្លែងនេសាទបម្រុងមានជាអាទិ៍ ទន្លេ ស្ទឹង ព្រែក បឹង អាងធម្មជាតិ ឬត្រពាំង ។ល។

***កន្លែងអភិរក្សជលផល:*** សំដៅដល់ចំណាត់ថ្នាក់នៃដែននេសាទទឹកសាប ឬសមុទ្រ ហើយត្រូវបានកំណត់ភូមិសាស្ត្រជាក់លាក់សម្រាប់វារីសត្វ ឬរុក្ខជាតិជ្រកពួន ពង កូន រីកធំធាត់ ឬរីកលូតលាស់។ កន្លែងអភិរក្សជលផលជាថ្នាលពូជ និងជាតំបន់ការពារធនធានជលផលដែលពុំអាចអនុញ្ញាតឱ្យប្រព្រឹត្តិ សកម្មភាពដែលនាំឱ្យមានផលប៉ះពាល់ដល់ធនធានជលផលបានឡើយ ក្រៅពីការស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផលស្របតាមគោលការណ៍ដ៏ត្រឹមត្រូវ ។

***ជម្រក :*** សំដៅដល់ទីកន្លែងសម្រាប់ជ្រកមួយដងមួយកាល ឬអចិន្ត្រៃយ៍របស់មច្ឆជាតិ និងវារីសត្វ ទោះបីតំបន់ទឹកសាប ឬសមុទ្រ។ ទីជម្រកទាំងនោះ រួមមានៈ កន្លែងអភិរក្សជលផល អន្លង់ជ្រៅៗតំបន់ព្រៃលិចទឹក តំបន់ផ្កាថ្ម តំបន់ស្មៅសមុទ្រ បឹងទន្លេសាប ស្រះ ឬ អន្លង់ជ្រៅៗនៅតាមវត្តតំបន់ការពារធម្មជាតិ និងកន្លែងអភិរក្សក្នុងកន្លែងនេសាទសហគមន៍។

***ជីវៈចម្រុះ :*** ជាបណ្តាសារពាង្គកាយរស់ពីគ្រប់ប្រភពទាំងអស់ រួមទាំងប្រព័ន្ធអេកូឡូស៊ី ដែនដីគោក ដែនសមុទ្រ ដែនទឹកសាប និងបណ្តាទំនាក់ទំនងអេកូឡូស៊ី ដែលនៅក្នុងនោះមានប្រព័ន្ធអេកូឡូស៊ីទាំងនេះ រួមមានទាំងបណ្តាសារពាង្គកាយ ខុសគ្នានៅក្នុងប្រភេទតែមួយ សារពាង្គកាយក្នុងប្រភេទផ្សេងគ្នា និងប្រព័ន្ធអេកូឡូស៊ីខុសៗគ្នា។

***វារីវប្បកម្ម :*** សំដៅដល់ការភ្ញាស់ ការបង្កាត់ ការចិញ្ចឹម ការបំប៉នពងត្រី កូនត្រី ត្រី ឬវារីសត្វ ឬការដាំការបណ្តុះពូជវារីរុក្ខជាតិ ក្នុងគោលបំណងធ្វើឱ្យកើនចំនួនឱ្យរីកលូតលាស់ ឬរីកធំធាត់ វារីសត្វ ឬវារីរុក្ខជាតិ។

***វារីសត្វ :*** សំដៅដល់ពួកសត្វបង្កកំណើតក្នុងទឹកមានជាអាទិ៍ មច្ឆជាតិ សិប្បីសត្វ ថលជលិកសត្វ បាណកសត្វ

ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀត ព្រមទាំងពង កូនរបស់វា ដែលរស់នៅជាសំខាន់ក្នុងទឹក ។ ប្រភេទវារីសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

***ឧទ្យានជាតិ*** **:** ជាតំបន់ធម្មជាតិក្នុងដែនដីគោក និង/ឬដែនទឹក ដែលត្រូវបានកំណត់ដើម្បីៈ

(ក) ការពារមុខងារតួនាទី ខាងផ្នែកអេកូឡូស៊ីនៃប្រព័ន្ធអេកូឡូស៊ីមួយឬច្រើន សម្រាប់ជាបយោជន៏ដល់មនុស្សជំនាន់នេះ និងជំនាន់ក្រោយ ។

(ខ) ក៏រិតដល់ការប្រើប្រាស់ ដែលធ្វើអោយខូចខាត បំផ្លិចបំផ្លាញដល់ធនធានជីវៈចំរុះ ធនធានធម្មជាតិ និងធនធានវប្បធម៌ និងមុខងារតួនាទីរបស់ជាមួយគោលបំណងនៃការកំណត់តំបន់នេះ។

(គ) ផ្តល់ជាមូលដ្ឋានសម្រាប់ជំនឿ ការស្រាវជ្រាវវិទ្យាសាស្ត្រ ការអប់រំ ការកំសាន្ត និងការទស្សនា ដែលគ្រប់សកម្មភាព ទាំងនេះ ពុំបង្កការគំរាមកំហែងដល់បរិស្ថាន និងវប្បធម៌ក្នុងមូលដ្ឋាន។

***ដែនជម្រកសត្វព្រៃ :*** ជាតំបន់ក្នុងដែនដីគោកឬដែនទឹក ដែលតំរូវឱ្យមានការធ្វើអន្តរាគមន៏យ៉ាងសកម្ម ដើម្បីបំពេញគោលបំណងគ្រប់គ្រង ការពារ និងធានាឱ្យមានការថែរក្សាទីជម្រក និង/ឬ ដើម្បីបំពេញល័ក្ខខ័ណ្ឌចាំបាច់ សម្រាប់ប្រភេទណាមួយ នៃសត្វ ឬរុក្ខជាតិ។

***បេតិកភ័ណ្ឌធម្មជាតិ*** **:** ជាតំបន់ក្នុងដែនដីគោក និង/ឬដែនទឹក ដែលក្នុងនោះមានលក្ខណៈពិសេស សំបូរដោយធម្មជាតិ ឬ ពាក់កណ្តាលធម្មជាតិ មានតម្លៃលេចធ្លោ ឬប្លែកពីគេដែលមានដោយកម្រ និងមានគុណភាពជាតំណាងឱ្យប្រព័ន្ធ ធម្មជាតិនានា ឬគុណភាពខាងផ្នែកសោភណ្ឌភាព ឬសារៈសំខាន់ខាងផ្នែកវប្បធម៌។

***ដែនបម្រុងធម្មជាតិ :*** ជាតំបន់នៃដែនដីគោក និង/ឬដែនទឹកប្រកបដោយប្រព័ន្ធអេកូឡូស៊ីមួយចំនួនមានៈ

- លក្ខណៈលេចធ្លោ ឬជាតំណាងនៃតំបន់ជាច្រើន និងមានលក្ខណៈពិសេសខាងផ្នែកភូគ្គសាស្ត្រ ឬសិរីរៈសាស្ត្រ
- ប្រភេទសត្វ ឬរុក្ខជាតិ ដែលមានតម្លៃសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ និង/ឬសម្រាប់ការសិក្សាតាមដានស្ថានភាពបរិស្ថាន។

***សហគមន៍តំបន់ការពារធម្មជាតិៈ*** ជាការចូលរួមរបស់ប្រជាសហគមន៏មូលដ្ឋាន និងជនជាតិភាគតិច ក្នុងចូលរួម

រៀបចំគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ធានាបាននូវការលើកកម្ពស់កំរិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់។

***តំបន់រ៉ាមសារ:*** ជាតំបន់ដីសើម ដែលគេចាត់ទុកថា ជាតំបន់មានសារៈសំខាន់ផ្នែកអេកូឡូស៊ី ជាលក្ខណៈអន្តរជាតិ។ (របាយការណ៍គ្រប់គ្រងធនធានព្រៃកោងកាង ទំព័រ ២៥)

***តំបន់ដីសើម*** : ជាតំបន់ដែលមានលក្ខណៈជាវាលភក់ វាលល្បប់ តំបន់មានរុក្ខជាតិពុករលួយ ទីដែលមានទឹកក្នុងលក្ខណៈធម្មជាតិ ឬសិប្បនិម្មិត ទឹកលិចជាអចិន្ត្រៃយ៍ ឬតាមរដូវ ឬទឹកនឹង ឬទឹកហូរ ឬ ទឹកភ្លាវរួមទាំងតំបន់សមុទ្ទ ដែល មានជម្រៅមិនលើសពី ៦ម៉ែត្រ ក្នុងពេលទឹកនាចទាបបំផុត។

## ៨. ឯកសារពិគ្រោះ

- ច្បាប់ស្តីពីជលផល, ២០០៦
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ២០០៥
- ឯកសារទស្សនៈទានការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន (CCB-NREM), ២០០៥
- ឯកសារអប់រំបរិស្ថានរបស់ក្រសួងបរិស្ថាន ២០០៥
- ឯកសារបច្ចេកទេសព្រៃឈើ (TA, Shambhu Prasad, Concern Worldwide), ២០០៤

## ៩. ឧបសម្ព័ន្ធ

***គំរូទី១***

**<u>ប្រកាស</u>**

កន្លែងអភិរក្សសហគមន៍នេសាទជាជម្រករក្សាពូជត្រី វារីសត្វ និងរុក្ខជាតិ សម្រាប់ជ្រកពួន ពងកូន រីកធំធាត់ ។

- ហាមឃាត់ដាច់ខាតការធ្វើនេសាទគ្រប់ប្រភេទ នៅក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ
- ហាមឃាត់បើកកាណូត ឬអុំទូក ឆ្លងកាត់ ឬធ្វើសកម្មភាពផ្សេងៗទៀត នៅក្នុងកន្លែងអភិរក្ស
- ការធ្វើនេសាទគ្រប់ប្រភេទត្រូវស្ថិតនៅចំងាយពីររយម៉ែត្រ (២០០ម) ពីព្រំប្រទល់កន្លែងអភិរក្សរបស់សហគមន៍នេសាទ
- ជនណាប្រព្រឹត្តបទល្មើសត្រូវឃាត់ខ្លួនជាបណ្តោះអាសន្ន រួចបញ្ជូនជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ច ឬរដ្ឋបាលជលផល ដើម្បីចាត់ការតាមផ្លូវច្បាប់ស្តីពីជលផល ។

ស.ន............................ថ្ងៃទី........ខែ..........ឆ្នាំ ២០០..

**សេចក្តីសម្រេចរបស់សហគមន៍នេសាទ**

**ប្រធានគណៈកម្មការ**

## គំរូទី២

## បទបញ្ជា ឬបម្រាម

## កន្លែងអភិរក្សសហគមន៍នេសាទ............

ដើម្បីធានាបានការគ្រប់គ្រង និងការពារកន្លែងអភិរក្សសហគមន៍នេសាទប្រកបដោយប្រសិទ្ធភាព សហគមន៍នេសាទសម្រេចដាក់ចេញនូវបទបញ្ជា/បម្រាមដូចខាងក្រោម :

**ប្រការ ១: គោលបំណងនៃការបង្កើតកន្លែងអភិរក្ស**

ដើម្បីអភិរក្សត្រី វារីសត្វ និងរុក្ខជាតិ ទុកជាពូជធារ ។

**ប្រការ ២: ហាមឃាត់**

- ការធ្វើនេសាទគ្រប់ប្រភេទនៅក្នុងកន្លែងអភិរក្ស
- ការធ្វើនាវាចរណ៍ឆ្លងកាត់ ឬធ្វើសកម្មភាពផ្សេងៗទៀតក្នុងកន្លែងអភិរក្ស
- ការតាំងទីលំនៅថ្មីនៅជុំវិញកន្លែងអភិរក្ស ដែលស្ថិតនៅតិចជាងពីរ (២)គីឡូម៉ែត្រ

**ប្រការ ៣:**

សកម្មភាពខាងលើ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសម្រាប់រដ្ឋបាលជលផលធ្វើការពិសោធន៍ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ។

**ប្រការ ៤:**

ជនណាប្រព្រឹត្តល្មើសនឹងប្រការ២ នៃបទបញ្ជាផ្ទៃក្នុងនេះ នឹងត្រូវទទួលការផាកពិន័យ អនុលោមទៅតាមច្បាប់ស្តីពីជលផល។

**ប្រការ ៥:**

បទបញ្ជាផ្ទៃក្នុងកន្លែងអភិរក្សសហគមន៍នេសាទនេះ បានអនុម័តដោយការប្រជុំរបស់សហគមន៍នេសាទ នៅថ្ងៃទី.....ខែ.....ឆ្នាំ២០០....និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយគណៈកម្មការសហគមន៍នេសាទ ។

## *គំរូទី ៣*

### ស្លាកសញ្ញាជាមួយរូបភាព និង បទបញ្ជា/បម្រាម

- ហាមចាប់ត្រីក្នុងកន្លែងអភិរក្ស
- ហាមចាប់ត្រីក្នុងកន្លែងអភិរក្សទោះបីឧបករណ៍ប្រភេទណាក៏ដោយ
- ហាមនេសាទគ្រប់ប្រភេទក្នុងកន្លែងអភិរក្ស
- ហាមចាប់ត្រីមេពូជក្នុងកន្លែងអភិរក្ស
- អភិរក្សពូជត្រីដើម្បីបន្តពូជ
- យើងនាំគ្នាថែរក្សាត្រីក្នុងកន្លែងអភិរក្ស
- សូមជួយថែរក្សា ការពារត្រីនៅក្នុងកន្លែងអភិរក្សឱ្យបានគង់វង្ស
- ប្តេជ្ញាចូលរួមការពារកន្លែងអភិរក្ស
- ហាមនេសាទគ្រប់ប្រភេទនៅកន្លែងអភិរក្ស
- សហគមន៍នេសាទប្តេជ្ញាការពារកន្លែងអភិរក្ស
- ជនណាប្រព្រឹត្តបទល្មើសនៅកន្លែងអភិរក្សត្រូវទទួលទោសតាមច្បាប់នេសាទ




**កន្លែងអភិរក្សជាថ្នាលបណ្តុះពូជមច្ឆជាតិ!**